ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.....ក.ប/ស.ជ.ស.ប.ប

សេចក្តីជូនដំណឹង
ស្តីពី
ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
សម្រាប់ពលករជំនាញទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានកិត្តិយស សូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងប្រព័ន្ធពលករជំនាញឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុននឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនសម្រាប់ពលករជំនាញ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

ល.រ	ប្រភេទតេស្ត	កាលបរិច្ឆេទធ្វើតេស្ត	មណ្ឌល	តម្លៃចុះឈ្មោះ
១	ភាសាជប៉ុន JFT-Basic	ថ្ងៃទី៣, ១៤ និង១៨ ខែធ្នូ ឆ្នាំ២០២៦ ថ្ងៃទី៥, ៦ និង១០ ខែមករា ឆ្នាំ២០២៧	វិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI)	៣៦ដុល្លារ
២	ផ្នែកកសិកម្ម	ថ្ងៃទី៣, ១៤ និង១៨ ខែធ្នូ ឆ្នាំ២០២៦ ថ្ងៃទី៥, ៦ និង១០ ខែមករា ឆ្នាំ២០២៧		៣៣ដុល្លារ
៣	ផ្នែកថែទាំ	ថ្ងៃទី៣, ១៤ និង១៨ ខែធ្នូ ឆ្នាំ២០២៦ ថ្ងៃទី៥, ៦ និង១០ ខែមករា ឆ្នាំ២០២៧		២៦ដុល្លារ
៤	ផ្នែកសំណង់	ថ្ងៃទី៣, ១៤ និង១៨ ខែធ្នូ ឆ្នាំ២០២៦ ថ្ងៃទី៥, ៦ និង១០ ខែមករា ឆ្នាំ២០២៧		៧ដុល្លារ

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- ព័ត៌មានអំពីមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  - ❖ វិទ្យាស្ថានអភិវឌ្ឍវិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរសព្ទ៖ +855 12 937 168 / +855 16 862 868 / +855 15 729 123 / +855 12 269 768
- សេវានៃការចុះឈ្មោះធ្វើតេស្ត គឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
- **ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖ លិខិតឆ្លងដែន**
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលទៅគេហទំព័រ https://ac.prometric-jp.com/testlist/ssw/index.html

បញ្ជាក់៖ កាលបរិច្ឆេទនៃការធ្វើតេស្តខាងលើនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញទាំង ៤ផ្នែកខាងលើ ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហោ សួរ

ចម្លងជូន៖
-សមាគមទីភ្នាក់ងារទេសន្តរប្រវេសន៍ការងារកម្ពុជា
-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
"ដើម្បីផ្សព្វផ្សាយ"
-ឯកសារ កាលប្បវត្តិ